ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ការរកឃើញ ០១ ករណីថ្មីទៀត ជាជនជាតិខ្មែរ ដែលមានវីរុសកូវីដ១៩ នៅខេត្តបន្ទាយមានជ័យ និងអ្នកព្យាបាលជាសះស្បើយ ចំនួន ០៨ នាក់ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត (០៥នាក់) នៅខេត្តបាត់ដំបង (០១នាក់) កំពង់ឆ្នាំង (០១នាក់) និងព្រះវិហារ(០១នាក់)

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពវីរុសកូវីដ ១៩ នៅទូទាំងប្រទេស៖ ត្រឹមម៉ោង០៩:០០ព្រឹក ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០**

- អ្នកព្យាបាលជាសះស្បើយសរុបចំនួន **២១នាក់** (បុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអង់គ្លេស ០១នាក់ បុរសជនជាតិបារាំង ០១នាក់ និងបុរសជនជាតិខ្មែរ ១៦នាក់) គិតចាប់ពីខែមករា ដល់បច្ចុប្បន្ននេះ
- អ្នកដែលកំពុងសម្រាកព្យាបាល សរុបចំនួន **៨២នាក់** (ស្ត្រី ២៦នាក់ និងបុរស ៥៦នាក់) នៅតាមមន្ទីរពេទ្យរដ្ឋ នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត
- អ្នកមានវីរុសកូវីដ១៩ ដែលបានរកឃើញនៅទូទាំងប្រទេស សរុបចំនួន **១០៣នាក់** (ស្ត្រី ២៨នាក់ និងបុរស ៧៥ នាក់) ។

**២. ករណីជាសះស្បើយ ចំនួន ០៨ ករណី មានដូចតទៅ៖**

- **មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត៖ ០៥នាក់ បានជាសះស្បើយ**

  បុរស អាយុ ៧៣ឆ្នាំ និងស្ត្រីអាយុ ៦៩ឆ្នាំ ជនជាតិអង់គ្លេស (០២នាក់) បុរសជនជាតិបារាំង អាយុ ៦៩ឆ្នាំ (០១នាក់) និង បុរសជាជនជាតិខ្មែរ អាយុ ២៧ឆ្នាំ និងអាយុ ៦៣ឆ្នាំ (០២នាក់) ដែលជាអ្នកវិលត្រឡប់មកពីចូលរួមសាសនានៅប្រទេសម៉ាឡេស៊ី បានជាសះស្បើយ ដែលត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យនៅថ្ងៃនេះ។

- **នៅថ្នាក់ខេត្ត៖ ០៣នាក់ បានជាសះស្បើយ**

  បុរសអាយុ ៣០ឆ្នាំ នៅខេត្តបាត់ដំបង បុរសអាយុ ៣៦ឆ្នាំ នៅខេត្តកំពង់ឆ្នាំង និងបុរសអាយុ ៣៩ឆ្នាំ (ដែលជាអ្នកវិលត្រឡប់មកពីចូលរួមសាសនានៅប្រទេសម៉ាឡេស៊ី) បានជាសះស្បើយ ដោយមានតេស្តអវិជ្ជមានចំនួន០២លើក ហើយត្រូវបានឲ្យវិលត្រឡប់ទៅផ្ទះវិញរួចហើយ។

**៣. ខេត្តបន្ទាយមានជ័យ៖ ០១ ករណីថ្មី វិជ្ជមានវីរុសកូវីដ១៩**

ស្ត្រីអាយុ ៣៦ឆ្នាំ បម្រើការនៅស្តាធីវី (Star TV) រស់នៅភូមិប៉ាលេឡៃ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត វិជ្ជមានវីរុសកូវីដ១៩ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តបន្ទាយមានជ័យ។

**៤. មិនត្រូវប្រើប្រាស់ឧបករណ៍ធ្វើតេស្តរហ័សរកវីរុសកូវីដ១៩ (Rapid Test ) ដោយខ្លួនឯង**

ក្រសួងសុខាភិបាល សូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ សូមកុំប្រើប្រាស់ឧបករណ៍ធ្វើតេស្តរហ័សរកវីរុសកូវីដ១៩ (Rapid Test ) ជាមធ្យោបាយក្នុងការរកវីរុសកូវីដ១៩ ដោយខ្លួនឯងឲ្យសោះ ។ បច្ចុប្បន្ន មានការផលិតឧបករណ៍ធ្វើតេស្តរហ័សច្រើន តែរហូតមកដល់ពេលនេះ នៅមិនទាន់មានឧបករណ៍ធ្វើតេស្តរហ័សរកវីរុស



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

កូវីដ១៩ប្រភេទណាមួយ ដែលមានការបញ្ជាក់ទទួលស្គាល់ពីអង្គការសុខភាពពិភពលោក នូវភាពត្រឹមត្រូវ និងប្រសិទ្ធិភាពនៃការធ្វើតេស្តរហ័សរកវីរុសកូវីដ១៩នេះ នៅឡើយទេ ជាពិសេស ប្រសិទ្ធិភាពនៃការធ្វើតេស្តរហ័សបែបនេះ គឺនៅទាបណាស់ ហើយក៏មានការចេញលទ្ធផលមកមិនច្បាស់លាស់ច្រើនណាស់ដែរ (អ្នកដែលមិនមានវីរុសកូវីដ១៩ បែរទៅជាមានលទ្ធផលវិជ្ជមាន រីឯអ្នកដែលមានវីរុសកូវីដ១៩ បែរទៅជាមានលទ្ធផលមិនមានវីរុសកូវីដ១៩)។ម្យ៉ាងវិញទៀត ឧបករណ៍សម្រាប់ធ្វើតេស្តរហ័សបែបនេះ មិនទាន់មានការទទួលស្គាល់ពីក្រសួងសុខាភិបាល ហើយជនណាដែលយកឧបករណ៍ធ្វើតេស្តរហ័សរកវីរុស កូវីដ១៩ មកធ្វើការផ្សព្វផ្សាយដើម្បីលក់ដូរជាសាធារណៈ ដោយមិនមានការអនុញ្ញាតពីក្រសួងសុខាភិបាល ត្រូវផ្តន្ទាទោសតាមផ្លូវច្បាប់ជាធរមាន។

ក្រសួងសុខាភិបាល សូមអំពាវនាវ សូមបងប្អូនប្រជាពលរដ្ឋ កុំប្រើប្រាស់ឧបករណ៍ធ្វើតេស្តរហ័សរកវីរុសកូវីដ១៩ ដោយខ្លួនឯង តាមការឃោសនាពីបុគ្គល ឬការផ្សព្វផ្សាយខុសច្បាប់មួយចំនួនបែបអនាធិបតេយ្យ។ក្រសួង សូមបញ្ជាក់ជូនសារជាថ្មីថា មានតែវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលកំពុងប្រតិបត្តិការតាមបច្ចេកទេស និងគោលការណ៍ប្រតិបត្តិស្តង់ដារបស់អង្គការសុខភាពពិភពលោក ដែលមានការចេញលទ្ធផលទទួលស្គាល់ត្រឹមត្រូវ។ ក្រសួងក៏សូមធ្វើការអំពាវនាវដល់អាជ្ញាធរពាក់ព័ន្ធ ឲ្យចាត់វិធានការតាមច្បាប់ជាធរមានយ៉ាងម៉ឺងម៉ាត់ជាទីបំផុត ចំពោះបុគ្គល ឬក្រុមហ៊ុនណាដែលធ្វើការផ្សព្វផ្សាយឧបករណ៍ធ្វើតេស្តរហ័សរកវីរុសកូវីដ១៩ ដោយមិនមានការអនុញ្ញាតពីក្រសួងសុខាភិបាល។

៥. លទ្ធផលដែលនឹងត្រូវទទួលបាននៅវេលាចន្លោះម៉ោង២២ទៅ២៣យប់ នៃថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០ នេះ នឹងជូនព័ត៌មានដល់សាធារណជននៅវេលាថ្ងៃស្អែកព្រឹកជាបន្តទៀត។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តនៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨។

ថ្ងៃអាទិត្យ ០៦កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា



ទីស្តីការក្រសួងសុខាភិបាល លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩